ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 22 / 03 / 2012
ម៉ោង (Time/Heure) : 10:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>

# <u>សាធារណៈ</u>

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្ដី - ថ្ងៃទី ៣៦

រៀបចំដោយៈ ឌុច ផារី និង Andrew MCINTYRE

| <u>កំណត់ហេតុអ្នកចូលរួម</u> |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណា, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី , លោក ដាវ អានសាន, លោក Andrew MCINTYRE |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក Vincent DE WILDE D'ESTMAEL, លោក ច័ន្ទ តារាស្មី, លោក Tarik ABDULHAK, លោក Dale LYSAK |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ (សហមេធាវី), លោក Michiel Pestman (សហមេធាវី) |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧតម (សហមេធាវី) លោក Michael Karnavas (សហមេធាវី) |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន (សហមេធាវី),លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ (សហមេធាវីនាំមុខ), លោកស្រី Elisabeth Simonneau-Fort (សហមេធាវីនាំមុខ), លោក ឡោ ជុនធី, លោកស្រី ស៊ិន សុវ៉ន, លោកស្រី ទីស្រីនណា, លោក Barnabé NEKUIE, លោក វ៉ែន ពៅ |
| សាក្សី៖ មិនមាន |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក កូវ កែវរតនះ, លោក ឡាយ ណារ៉ា |
| ផ្សេងៗ៖ កញ្ញា Alexandra PRASSOLOFF |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទ ១៤ ខែ មីនា ឆ្នាំ ២០១២ | ចាប់ផ្ដើមម៉ោង៖ ៩.00 | បញ្ចប់ម៉ោង៖ ១៥.៥៥ |
| សម្រាកព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៣០ | បញ្ចប់ម៉ោង៖ ១០.៥០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.00 | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៣០ | បញ្ចប់ម៉ោង៖ ១៤.៥៥ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ៤ ម៉ោង និង ៤០ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់ដោយផ្ទាល់មាត់របស់មេធាវីការពារក្ដី | សហព្រះរាជអាជ្ញា | ៩.0២ | ១៤.៣០ |
| ការលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្ដី អៀង សារី<br>មេធាវីការពារក្ដី នួន ជា | ១០.២៧<br>១២.00 | ១០.២៧<br>១២.00 |
| ការឆ្លើយតបរបស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងការជំទាស់ដោយផ្ទាល់មាត់របស់មេធាវីការពារក្ដី | មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ១៤.៥៤ | ១៥.៤០ |

| | | | |
|---|---|---|---|
| សំណើរបស់មេធាវីការពារក្តី នួន ជា | មេធាវីការពារក្តី នួន ជា<br>អង្គជំនុំជម្រះ<br>មេធាវីការពារក្តី អៀង សារី | ១៥.៤៤ | ១៥.៥៥ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ ។

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងការជំទាស់ដោយផ្ទាល់មាត់របស់មេធាវីការពារក្តី**

សហព្រះរាជអាជ្ញាធ្វើការកែតម្រូវទៅលើឯកសារមួយចំនួនដែលបានយោងកាលពីថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ ។ បន្ទាប់មកសហព្រះរាជអាជ្ញាបន្តការឆ្លើយតបទៅនឹងការជំទាស់លើឯកសារដែលបានធ្វើឡើងដោយមេធាវីការពារក្តី ។

**ការលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់**

ជនជាប់ចោទ អៀង សារី និង នួន ជា តាមរយៈមេធាវីរបស់គាត់ ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ តែសុំចូលរួមសវនាការពីចំងាយតាមរយៈប្រព័ន្ធសោតទ្សន៍។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមការស្នើសុំ (លិខិតលះបង់សិទ្ធិគឺត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ) ។

**ការឆ្លើយតបរបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងការជំទាស់ដោយផ្ទាល់មាត់របស់មេធាវីការពារក្តី**

មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើការឆ្លើយតបទៅនឹងការជុំទាស់ដោយផ្ទាល់មាត់ទៅលើឯកសារ ដែលបានលើកឡើងដោយមេធាវីការពារក្តី ។

**សំណើរបស់មេធាវីការពារក្តី នួន ជា**

មេធាវីការពារក្តី នួន ជា ស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះនូវរយៈពេល ១៥ នាទី (ក្នុងអំឡុងពេលសវនាការបន្ទាប់) ដើម្បីលើកឡើងអំពីបញ្ហាកាលវិភាគសម្រាប់ការស្តាប់សក្ខីកម្មរបស់សាក្សីឈ្មោះ កាំង ហ្កេចអ៊ាវ ហៅ ឌុច TCW-281 ។

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឱ្យជនជាប់ចោទ អៀង សារី (ម៉ោង ១០.២៧) និង នួន ជា (ម៉ោង ១២.០០) ចូលរួមដំណើរការសវនាការពីបន្ទប់រង់ចាំនៅខាងក្រោមសាលសវនាការតាមរយៈប្រព័ន្ធសោតទស្សន៍ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោទស្សន៍ទៅបន្ទប់រង់ចាំ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី, នួន ជា និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់បន្ទប់សវនាការវិញឱ្យបានមុនម៉ោង ៩ ព្រឹក នៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២។

| ការលើកពេលវេលាសវនាការបន្ត៖ |
|---|
| សវនាការនឹងបន្តនៅថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១២ វេលាម៉ោង ៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

ឌុច ផារី Andrew MCINTYRE